រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ៥ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១០០១ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២

# ប្រកាសរួម
# ស្តីពី
# ការផ្តល់សេវាសាធារណៈរបស់ក្រសួងយុត្តិធម៌

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA. Phone: 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១** :

អនុញ្ញាតឱ្យក្រសួងយុត្តិធម៌ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

**ប្រការ ២** :

ក្រសួងយុត្តិធម៌ ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រសួងយុត្តិធម៌ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវជាដើម។

**ប្រការ ៣** :

ក្រសួងយុត្តិធម៌ មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមជានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

**ប្រការ ៤** :

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៥** :

ក្រសួងយុត្តិធម៌ ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ ៦** :

ក្រសួងយុត្តិធម៌ ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៧** :

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបាន តាមការចាំបាច់ តាមរយៈប្រកាសរួម។

**ប្រការ ៨** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩** :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍានៈ**

**ចម្លងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

**«ដើម្បីជូនជ្រាប»**
- ដូចប្រការ ៩ **«ដើម្បីអនុវត្ត»**
- ឯកសារ - កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ

## ភ្ជាប់នឹងប្រកាសរួមលេខ ១០០១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

## ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងយុត្តិធម៌

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| I. | **សេវាសាធារណៈស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់ក្រសួងយុត្តិធម៌** | | | |
| 1 | ការចេញព្រឹត្តិបត្រថ្កោលទោសលេខ 3 | | | |
| 1.1 | ព្រឹត្តិបត្រថ្កោលទោស (ជនជាតិខ្មែរ ក្រៅពីសិស្ស និងនិស្សិត) | 30,000 | 20ថ្ងៃ | 3ខែ |
| | | 60,000 | 12ថ្ងៃ | 3ខែ |
| 1.2 | ព្រឹត្តិបត្រថ្កោលទោស(ជនជាតិខ្មែរជាសិស្ស ឬនិស្សិត ) | 10,000 | 20ថ្ងៃ | 3ខែ |
| | | 20,000 | 12ថ្ងៃ | 3ខែ |
| 1.3 | ព្រឹត្តិបត្រថ្កោលទោស (ជនជាតិបរទេស) | 250,000 | 20ថ្ងៃ | 3ខែ |
| | | 500,000 | 12ថ្ងៃ | 3ខែ |
| 1.4 | បកប្រែជាភាសាបរទេស(ព្រឹត្តិបត្រថ្កោលទោស) | 40,000 | 20ថ្ងៃ | 3ខែ |
| | | 60,000 | 12ថ្ងៃ | 3ខែ |
| II. | **សេវាសាធារណៈនៅតាមសាលាជម្រះក្តី** | | | |
| 1 | ពន្ធដាក់ពាក្យបណ្តឹង(គិតតាមតម្លៃកម្មវត្ថុនៃបណ្តឹង ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី) | | | |
| 1.1 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃត្រឹម 10លានរៀល | 1% នៃតម្លៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 1.2 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃលើសពី 10លាន ដល់ 100លានរៀល | (10លាន ×1%)+ (ភាគតម្លៃលើសពី 10លាន×0.7%) | | |
| 1.3 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃលើសពី 100លាន ដល់ 1000លានរៀល | (10លាន ×1%)+ (90លាន×0.7%)+ (ភាគតម្លៃលើសពី 100លាន×0.3%) | | |
| 1.4 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃលើសពី 1000លានរៀល | (10លាន ×1%)+ (90លាន×0.7%)+ (900លាន×0.3%)+ (ភាគតម្លៃលើសពី 1000លាន×0.1%) | | |
| 2 | ពន្ធដាក់ពាក្យបណ្តឹងឧបាស្រ័យ | | | |
| 2.1 | ពន្ធដាក់ពាក្យបណ្តឹងឧទ្ធរណ៍ | 1.5ដង នៃពន្ធដែលបានបង់រួចនៅសាលាដំបូង | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 2.2 | ពន្ធដាក់ពាក្យបណ្តឹងសាទុក្ខទៅតុលាការកំពូល | 2ដង នៃពន្ធដែលបានបង់រួចនៅសាលាដំបូង | | |
| 3 | ពន្ធដាក់ពាក្យបណ្តឹងជំនុំជម្រះសារជាថ្មី ( សាលាជម្រះក្តីគ្រប់ថ្នាក់ ) | 10,000 | | |
| 4 | ពន្ធដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន( សាលាជម្រះក្តីដំបូង ) | 1/2នៃប្រាក់ពន្ធដែលគណនាតាមតម្លៃនៃកម្មវត្ថុបណ្តឹង | | |
| 5 | ពន្ធដាក់ពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្តី ក្រៅពីពន្ធទាំងឡាយដែលបានរៀបរាប់ខាងលើ (មាន 17 ប្រភេទ បានចែងក្នុងឧបសម្ព័ន្ធ 1 នៃប្រកាសលេខ 28 កយ ប្រក/07 របស់ក្រសួងយុត្តិធម៌ ) | 5,000 | | |
| 5.1 | ពាក្យប្តឹងជិតចិត្ត (មាត្រា 28) | 5,000 | | |
| 5.2 | ពាក្យសុំចូលរួមជួយអន្តរាគមន៍ ពាក្យសុំចូលរួមអន្តរាគមន៍ ក្នុងសហបណ្តឹង ( មាត្រា 43, 49 ) | 5,000 | | |
| 5.3 | ពាក្យសុំឲ្យថែរក្សាការពារភស្តុតាងដែលធ្វើមុនពេលដាក់ពាក្យបណ្តឹង ( មាត្រា 164, កថាខណ្ឌទី2 ) | 5,000 | | |
| 5.4 | ពាក្យប្តឹងទាស់ ( មាត្រា 204 ) | 5,000 | | |
| 5.5 | ពាក្យប្តឹងជំទាស់ ( មាត្រា 301 ) | 5,000 | | |
| 5.6 | ពាក្យសុំតវ៉ាចំពោះការអនុវត្ត ( មាត្រា 344 ) | 5,000 | | |
| 5.7 | ពាក្យសុំឲ្យចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ( មាត្រា 353 ) | 5,000 | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 5.8 | ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ( មាត្រា 362 ) | 5,000 | | |
| 5.9 | ពាក្យសុំឲ្យផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ ( មាត្រា 366, 367, 369 ) | 5,000 | | |
| 5.1 | ពាក្យសុំឲ្យដីកាសម្រេចបង្គាប់ឲ្យប្រគល់( មាត្រា 390, 450, 459, 483 ) | 5,000 | | |
| 5.11 | ពាក្យសុំទាមទារឲ្យចែកចំណែក (មាត្រា 394, 409, 426 ) | 5,000 | | |
| 5.12 | ពាក្យសុំការចាត់ចែងការរក្សាការពារ ( មាត្រា 429 ) | 5,000 | | |
| 5.13 | ពាក្យសុំឲ្យលុបចោលនីតិវិធីលក់ដោយបង្ខំដោយដាក់ប្រាក់ធានា ( មាត្រា 461 ) | 5,000 | | |
| 5.14 | ពាក្យសុំការអនុញ្ញាតឲ្យនាវាធ្វើដំណើរ (មាត្រា 462 ) | 5,000 | | |
| 5.15 | ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ( មាត្រា 550 ) | 5,000 | | |
| 5.16 | ពាក្យសុំឲ្យផ្អាកការអនុវត្តរក្សាការពារ ( មាត្រា 551 ) | 5,000 | | |
| 5.17 | ពាក្យសុំឲ្យលុបចោលដីកាសម្រេចរក្សាការពារ ( មាត្រា 557, 558, 559) | 5,000 | | |
| 6 | ពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាព ក្រៅពីពន្ធដាក់ពាក្យសុំទៅតុលាការឲ្យសម្រេចសេចក្តីទាំង 17ខាងលើ ( មាន 4 ប្រភេទ បានចែងក្នុងឧបសម្ព័ន្ធ 2 ក្នុងប្រកាសលេខ 28 កយ.ប្រក/07 របស់ក្រសួងយុត្តិធម៌ ) | | | |
| 6.1 | ការទាមទារមើល ឬការទាមទារថតចម្លងសំណុំរឿង ។ ប៉ុន្តែក្នុងករណី ដែលភាគីទាមទារនៅពេលដែលរឿងក្តីកំពុងចាត់ការមិនតម្រូវឲ្យបង់ទេ ។ ចំពោះការចំណាយក្នុងការថតចម្លងឯកសារសំណុំរឿង ជាបន្ទុករបស់អ្នកទាមទារ ។ ( មាត្រា 258, 378, 538 ) | 5,000 ក្នុងមួយដង | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 6.2 | ការប្រគល់ឯកសារចម្លងយថាភូត ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬឯកសារដកស្រង់នៃសំណុំរឿង ( មាត្រា 258, 378, 538 ) | 5,000 ក្នុងឯកសារ 1 ឈុត | | |
| 6.3 | ការប្រគល់នូវលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្តីសម្រេច ( មាត្រា 258, 378, 355 កថាខណ្ឌ 2 ជាអាទិ៍ ) | 5,000 ក្នុងឯកសារ 1 ឈុត | | |
| 6.4 | ពាក្យសុំឲ្យផ្តល់រូបមន្តអនុវត្ត ( មាត្រា 355 ជាអាទិ៍ ) | 5,000 | | |
| 7 | ប្រាក់ពិន័យផ្សេងៗ ដែលទទួលបានពីការសម្រេចរបស់តុលាការ | តាមសេចក្តីសម្រេចរបស់តុលាការ | | |

**បញ្ជាក់:** ចំពោះរូបមន្តនៃតម្លៃសេវាលើពន្ធដាក់ពាក្យបណ្តឹងគ្រប់ប្រភេទ ដែលចែងក្នុងតារាងឧបសម្ព័ន្ធនេះ ត្រូវបានធ្វើការគណនាចេញជាចំនួនទឹកប្រាក់រួចជាស្រេចទៅតាមទំហំតម្លៃកម្មវត្ថុនៃបណ្តឹង សម្រាប់អ្នកប្រមូលចំណូលនៅតាមសាលាជម្រះក្តីប្រើជាមូលដ្ឋាន ដូចមានរាយលម្អិតនៅក្នុង«តារាងនៃពន្ធដាក់ពាក្យបណ្តឹងពន្ធដាក់ពាក្យបណ្តឹងឧទ្ធរណ៍ និងពន្ធដាក់ពាក្យបណ្តឹងសាទុក្ខ តាមតម្លៃកម្មវត្ថុនៃបណ្តឹង» ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌ និងមានជំនួយឧបត្ថម្ភដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០០៧ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១២

# ប្រកាសរួម
# ស្តីពី
# ការផ្តល់ទ្វារលើកទឹកចិត្តជូន
# ក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St,92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យ សាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងប្រកាសរួមលេខ ១០០១ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ ១** :

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ ២** :

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា រវាងរដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនឹងសាលាដំបូងរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយផ្អែកលើភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងការផ្តល់សេវាសាធារណៈដែលអនុវត្តដោយសាលាដំបូងរាជធានី ខេត្ត ។

**ប្រការ ៣** :

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ និងសាលាដំបូងរាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួនពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ១០០១ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងយុត្តិធម៌។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនរដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ និង សាលាដំបូងរាជធានី ខេត្ត សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងយុត្តិធម៌ និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៤ :**

ការផ្តល់ប្រាក់រង្វាន់ជូនក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ៖

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងយុត្តិធម៌ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ

ខ. ការបែងចែកសម្រាប់សាលាដំបូងរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនសាលាដំបូងរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ

**ប្រការ ៥ :**

រដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ និង សាលាដំបូងរាជធានី ខេត្ត ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សាលាដំបូងរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀត របស់រដ្ឋបាលកណ្តាល និង សាលាដំបូងរាជធានី ខេត្ត នៃក្រសួងយុត្តិធម៌ដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ (ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. ផ្នែកចំណូលៈ ត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ចំណូលដែលបានបុរេប្រទាន ៖

- ចំពោះរដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយ នូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រម ទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូល មិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ ចំណូលនោះ។
- ចំពោះសាលាដំបូងរាជធានី ខេត្ត ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូល មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែល បានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវចេញលិខិតពិនិត្យបញ្ជាក់ លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

ខ. ផ្នែកចំណាយៈ ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទាន ដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ ៦** :

ក្រោយពីបានបំពេញនីតិវិធី ដែលមានចែងក្នុងប្រការ ៥ ខាងលើ ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្ត ដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងយុត្តិធម៌ ត្រូវអនុលោមតាមការសម្រេចរបស់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការ សម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែក តាមគុណសម្បត្តិការងារ។

**ប្រការ ៧** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨** :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍានះ**

**ចម្លងជូនៈ**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត

**«ដើម្បីជូនជ្រាប»**

- ដូចប្រការ ៨ **«ដើម្បីអនុវត្ត»**
- ឯកសារ - កាលប្បវត្តិ

**តារាងឧបសម្ព័ន្ធ**

**ភ្ជាប់នឹងប្រកាសរួមលេខ ១០០២ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២**

**ស្តីពីការផ្តល់ទឹកប្រាក់លើកទឹកចិត្ត ជូនក្រសួងយុត្តិធម៌(ក. យ) និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ក. សហវ)**

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. យ | ក. សហវ |
| **I. សេវាសាធារណៈស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់ក្រសួងយុត្តិធម៌** | | | | |
| 1 | ការចេញព្រឹត្តិបត្រថ្កោលទោសលេខ 3 | | | |
| 1.1 | ព្រឹត្តិបត្រថ្កោលទោស (ជនជាតិខ្មែរ ក្រៅពីសិស្ស និងនិស្សិត) | 30% | 69% | 1% |
| | | 30% | 69% | 1% |
| 1.2 | ព្រឹត្តិបត្រថ្កោលទោស(ជនជាតិខ្មែរជាសិស្ស ឬនិស្សិត) | 30% | 69% | 1% |
| | | 30% | 69% | 1% |
| 1.3 | ព្រឹត្តិបត្រថ្កោលទោស (ជនជាតិបរទេស) | 30% | 69% | 1% |
| | | 30% | 69% | 1% |
| 1.4 | បកប្រែជាភាសាបរទេស(ព្រឹត្តិបត្រថ្កោលទោស) | 10% | 89% | 1% |
| | | 10% | 89% | 1% |
| **II. សេវាសាធារណៈនៅតាមសាលាជម្រះក្តី** | | | | |
| 1 | ពន្ធដាក់ពាក្យបណ្តឹង(គិតតាមតម្លៃកម្មវត្ថុនៃបណ្តឹង ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី) | | | |
| 1.1 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃត្រឹម 10លានរៀល | 50% | 49% | 1% |
| 1.2 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃលើសពី 10លាន ដល់ 100លានរៀល | 50% | 49% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. យ | ក. សហវ |
| 1.3 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃលើសពី 100លាន ដល់ 1000លានរៀល | 50% | 49% | 1% |
| 1.4 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃលើសពី 1000លានរៀល | 50% | 49% | 1% |
| 2 | ពន្ធដាក់ពាក្យបណ្តឹងឧបាស្រ័យ | | | |
| 2.1 | ពន្ធដាក់ពាក្យបណ្តឹងឧទ្ធរណ៍ | 50% | 49% | 1% |
| 2.2 | ពន្ធដាក់ពាក្យបណ្តឹងសាទុក្ខទៅតុលាការកំពូល | 50% | 49% | 1% |
| 3 | ពន្ធដាក់ពាក្យបណ្តឹងជំនុំជម្រះសារជាថ្មី ( សាលាជម្រះក្តីគ្រប់ថ្នាក់ ) | 50% | 49% | 1% |
| 4 | ពន្ធដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន( សាលាជម្រះក្តីដំបូង ) | 50% | 49% | 1% |
| 5 | ពន្ធដាក់ពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្តី ក្រៅពីពន្ធទាំងឡាយដែលបានរៀបរាប់ខាងលើ ( មាន 17 ប្រភេទ បានចែងក្នុងឧបសម្ព័ន្ធ 1 នៃប្រកាសលេខ 28 កយ ប្រក/07 របស់ក្រសួងយុត្តិធម៌ ) | 10% | 89% | 1% |
| 5.1 | ពាក្យប្តឹងជិតចិត្ត(មាត្រា 28) | 10% | 89% | 1% |
| 5.2 | ពាក្យសុំចូលរួមជួយអន្តរាគមន៍ ពាក្យសុំចូលរួមអន្តរាគមន៍ ក្នុងសហបណ្តឹង ( មាត្រា 43, 49 ) | 10% | 89% | 1% |
| 5.3 | ពាក្យសុំឲ្យថែរក្សាការពារភស្តុតាងដែលធ្វើមុនពេលដាក់ពាក្យបណ្តឹង ( មាត្រា 164, កថាខណ្ឌទី2 ) | 10% | 89% | 1% |
| 5.4 | ពាក្យប្តឹងទាស់ ( មាត្រា 204 ) | 10% | 89% | 1% |
| 5.5 | ពាក្យប្តឹងជំទាស់ ( មាត្រា 301 ) | 10% | 89% | 1% |
| 5.6 | ពាក្យសុំតវ៉ាចំពោះការអនុវត្ត ( មាត្រា 344 ) | 10% | 89% | 1% |
| 5.7 | ពាក្យសុំឲ្យចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ( មាត្រា 353 ) | 10% | 89% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. យ | ក. សហវ |
| 5.8 | ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ( មាត្រា 362 ) | 10% | 89% | 1% |
| 5.9 | ពាក្យសុំឲ្យផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ ( មាត្រា 366, 367, 369 ) | 10% | 89% | 1% |
| 5.1 | ពាក្យសុំឲ្យដីកាសម្រេចបង្គាប់ឲ្យប្រគល់( មាត្រា 390, 450, 459, 483 ) | 10% | 89% | 1% |
| 5.11 | ពាក្យសុំទាមទារឲ្យចែកចំណែក (មាត្រា 394, 409, 426 ) | 10% | 89% | 1% |
| 5.12 | ពាក្យសុំការចាត់ចែងការរក្សាការពារ ( មាត្រា 429 ) | 10% | 89% | 1% |
| 5.13 | ពាក្យសុំឲ្យលុបចោលនីតិវិធីលក់ដោយបង្ខំដោយដាក់ប្រាក់ធានា ( មាត្រា 461 ) | 10% | 89% | 1% |
| 5.14 | ពាក្យសុំការអនុញ្ញាតឲ្យនាវាធ្វើដំណើរ (មាត្រា 462 ) | 10% | 89% | 1% |
| 5.15 | ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ( មាត្រា 550 ) | 10% | 89% | 1% |
| 5.16 | ពាក្យសុំឲ្យផ្អាកការអនុវត្តរក្សាការពារ ( មាត្រា 551 ) | 10% | 89% | 1% |
| 5.17 | ពាក្យសុំឲ្យលុបចោលដីកាសម្រេចរក្សាការពារ ( មាត្រា 557, 558, 559) | 10% | 89% | 1% |
| 6 | ពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាព ក្រៅពីពន្ធដាក់ពាក្យសុំទៅតុលាការឲ្យសម្រេចសេចក្តីទាំង 17ខាងលើ ( មាន 4 ប្រភេទ បានចែងក្នុងឧបសម្ព័ន្ធ 2 ក្នុងប្រកាសលេខ 28 កយ.ប្រក/07 របស់ក្រសួងយុត្តិធម៌ ) | | | |
| 6.1 | ការទាមទារមើល ឬការទាមទារថតចម្លងសំណុំរឿង ។ ប៉ុន្តែក្នុងករណី ដែលភាគីទាមទារនៅពេលដែលរឿងក្តីកំពុងចាត់ការមិនតម្រូវឲ្យបង់ទេ ។ ចំពោះការចំណាយក្នុងការថតចម្លងឯកសារសំណុំរឿង ជាបន្ទុករបស់អ្នកទាមទារ ។ ( មាត្រា 258, 378, 538 ) | 10% | 89% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. យ | ក. សហវ |
| 6.2 | ការប្រគល់ឯកសារចម្លងយថាភូត ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬឯកសារដកស្រង់នៃសំណុំរឿង ( មាត្រា 258, 378, 538 ) | 10% | 89% | 1% |
| 6.3 | ការប្រគល់នូវលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្តីសម្រេច ( មាត្រា 258, 378, 355 កថាខណ្ឌ 2 ជាអាទិ៍ ) | 10% | 89% | 1% |
| 6.4 | ពាក្យសុំឲ្យផ្តល់រូបមន្តអនុវត្ត ( មាត្រា 355 ជាអាទិ៍ ) | 10% | 89% | 1% |
| 7 | ប្រាក់ពិន័យផ្សេងៗ ដែលទទួលបានពីការសម្រេចរបស់តុលាការ | 75% | 24% | 1% |
| III. **ប្រាក់ចំណូលផ្សេងៗនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់** | | | | |
| 1 | ប្រាក់លក់ឡាយឡុងពីវត្ថុចាប់យក រឹបអូសជាទ្រព្យសម្បត្តិរដ្ឋ | 80% | 19% | 1% |

**បញ្ជាក់:** ចំពោះចំណូលដែលប្រមូលបានពីការផ្តល់សេវាសាធារណៈដោយសាលាដំបូងរាជធានី ខេត្ត ការផ្តល់រង្វាន់លើកទឹកចិត្តជូនសាលាដំបូងរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវអនុវត្តដូចអត្រាដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនេះ។

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១០០៣ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០១៣

# ប្រកាសរួម
# ស្ដីពី
# ការផ្ដល់សេវាសាធារណៈរបស់ក្រសួងព័ត៌មាន

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងព័ត៌មាន



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល និងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ របស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រសួងព័ត៌មាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១** :

អនុញ្ញាតឱ្យក្រសួងព័ត៌មាន អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

**ប្រការ ២** :

ក្រសួងព័ត៌មាន ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រសួងព័ត៌មាន ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវជាដើម។

**ប្រការ ៣** :

ក្រសួងព័ត៌មាន មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

**ប្រការ ៤ :**

ការបែងចែកភារកិច្ចលើការគ្រប់គ្រង ការប្រមូលចំណូល ពីការផ្តល់សេវាសាធារណៈ រវាងរដ្ឋបាលកណ្តាល នៃក្រសួងព័ត៌មាន និងមន្ទីរព័ត៌មានរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន។ ក្រសួងព័ត៌មាន ត្រូវផ្ញើសេចក្តីប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

**ប្រការ ៥ :**

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៦ :**

ក្រសួងព័ត៌មាន ត្រូវកំណត់ទីតាំងដាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ ៧ :**

ក្រសួងព័ត៌មាន ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៨ :**

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបាន តាមការចាំបាច់តាមរយៈប្រកាសរួម។

**ប្រការ ៩ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងព័ត៌មាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

ខៀវ កាញារីទ្ធ

ចម្លងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

«ដើម្បីជូនជ្រាប»
- ដូចប្រការ ១០ «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ
## ភ្ជាប់នឹងប្រកាសរួមលេខ ១០០៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២
## ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងព័ត៌មាន

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 1 | ផ្សព្វផ្សាយពាណិជ្ជកម្មតាមប៉ាណូ | | | |
| | - រយៈពេល 1ឆ្នាំ | 1,200,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - រយៈពេល 6ខែ | 800,000 | 7ថ្ងៃ | 6ខែ |
| | - រយៈពេល 3ខែ | 400,000 | 7ថ្ងៃ | 3ខែ |
| 2 | ផ្សព្វផ្សាយពាណិជ្ជកម្មតាមមធ្យោបាយដឹកជញ្ជូនផ្សេងៗ | | | |
| | - រយៈពេល 1ឆ្នាំ | 400,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - រយៈពេល 6ខែ | 200,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - រយៈពេល 3ខែ | 100,000 | 7ថ្ងៃ | 1ឆ្នាំ |
| 3 | ផ្សព្វផ្សាយពាណិជ្ជកម្មតាមអាហ្វីស | 200,000 | 7ថ្ងៃ | 1ឆ្នាំ |
| 4 | ផ្សព្វផ្សាយពាណិជ្ជកម្មតាមប័ណ្ណប្រកាស (គ្រាន់តែផ្តល់គំរូប័ណ្ណប្រកាសមកក្រសួង/មន្ទីរព័ត៌មាន) | មិនគិតថ្លៃ | 7ថ្ងៃ | 1ឆ្នាំ |
| 5 | ភ្នាក់ងារផ្សព្វផ្សាយពាណិជ្ជកម្ម | | | |
| | - បើក | 1,200,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាព | 800,000 | 7ថ្ងៃ | 1ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 6 | រាល់លិខិតអនុញ្ញាតសម្រាប់ឃោសនាមហាជន | មិនគិតថ្លៃ | 7ថ្ងៃ | 1ឆ្នាំ |
| 7 | អាជីវកម្មគ្រឹះស្ថានបោះពុម្ពផ្សាយ | | | |
| | - បើក | 1,200,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាព | 600,000 | 7ថ្ងៃ | 1ឆ្នាំ |
| 8 | អាជីវកម្មរោងពុម្ព | | | |
| | - បើក | 800,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាព | 400,000 | 7ថ្ងៃ | 1ឆ្នាំ |
| 9 | សមាគមវិទ្យុ និងទូរទស្សន៍ | | | |
| | - បើក | 200,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាព | 100,000 | 7ថ្ងៃ | 1ឆ្នាំ |
| 10 | - បើកអាជីវកម្មស្ថានីយវិទ្យុផ្សាយផ្ទាល់, វិទ្យុផ្សាយបន្ត, ទូរទស្សន៍ផ្សាយផ្ទាល់-បន្ត, ទូរទស្សន៍ខ្សែកាប និងទូរទស្សន៍ផ្សាយតាមប្រព័ន្ធផ្សេងៗ (MMDS, MUDS...) | មិនគិតថ្លៃ | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាពអាជីវកម្មស្ថានីយវិទ្យុផ្សាយផ្ទាល់ | 400,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាពអាជីវកម្មស្ថានីយវិទ្យុផ្សាយបន្ត | 200,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាពអាជីវកម្មស្ថានីយទូរទស្សន៍ផ្សាយផ្ទាល់ | 800,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាពអាជីវកម្មស្ថានីយទូរទស្សន៍ផ្សាយបន្ត | 300,000 | 7ថ្ងៃ | 1ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - បន្តសុពលភាពអាជីវកម្មស្ថានីយទូរទស្សន៍ផ្សាយតាមប្រព័ន្ធផ្សេងៗ (ខ្សែកាប, MMDS, MUDS...) នៅរាជធានីភ្នំពេញ | 800,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាពអាជីវកម្មស្ថានីយទូរទស្សន៍ផ្សាយតាមប្រព័ន្ធផ្សេងៗ(ខ្សែកាប, MMDS, MUDS...) កំរិតស្រុក ឬឃុំសង្កាត់ | 400,000 | 7ថ្ងៃ | 1ឆ្នាំ |
| 11 | អាជីវកម្មផ្សាយតាមប្រព័ន្ធអេឡិចត្រូនិច | | | |
| | - បើក | 400,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាព | 80,000 | 7ថ្ងៃ | 1ឆ្នាំ |
| 12 | សេវាត្រួតពិនិត្យ | | | |
| | - ស្ថានីយវិទ្យុប្រចាំឆ្នាំ | 200,000 | | 1ឆ្នាំ |
| | - ស្ថានីយទូរទស្សន៍ប្រចាំឆ្នាំ | 400,000 | | 1ឆ្នាំ |
| | - ពិសេសបន្ទាន់តាមស្ថានីយវិទ្យុ ទូរទស្សន៍ | 1,200,000 | គ្មាន | គ្មាន |
| 13 | អាជីវកម្មកាសែតផ្សាយភាសាជាតិ ឬភាសាបរទេស | | | |
| | - បើក | 400,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាព | 50,000 | 7ថ្ងៃ | 1ឆ្នាំ |
| 14 | អាជីវកម្មកាសែតផ្សាយជាភាសាបរទេស និងភាសាជាតិ | | | |
| | - បើក | 500,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាព | 100,000 | 7ថ្ងៃ | 1ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 15 | អាជីវកម្មទស្សនាវដ្តី | | | |
| | - បើក(ភាសាជាតិ) | 600,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បើក (ភាសាបរទេស ឬភាសាជាតិ និងបរទេស) | 800,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាព | 80,000 | 7ថ្ងៃ | 1ឆ្នាំ |
| 16 | អាជីវកម្មព្រឹត្តបត្រភាសាជាតិ | | | |
| | - បើក(ភាសាជាតិ) | 400,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បើក (ភាសាបរទេស ឬភាសាជាតិ និងបរទេស) | 500,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាព | 40,000 | 7ថ្ងៃ | 1ឆ្នាំ |
| 17 | ប្តូរឈ្មោះកាសែតភាសាជាតិ កាសែតភាសាបរទេស, ទស្សនាវដ្តីភាសាជាតិ ទស្សនាវដ្តីភាសា | 300,000 | 7ថ្ងៃ | 1ឆ្នាំ |
| 18 | ផ្ទេរសិទ្ធិកាសែត, ទស្សនាវដ្តីព្រឹត្តបត្រភាសាជាតិ និងភាសាបរទេស | 600,000 | 7ថ្ងៃ | 1ឆ្នាំ |
| 19 | អាជីវកម្មនាំចូលកាសែត និងទស្សនាវដ្តី | | | |
| | - បើក | 400,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បន្តសុពលភាព | 100,000 | 7ថ្ងៃ | 1ឆ្នាំ |
| 20 | បង្កើតសមាគមសារព័ត៌មាន | 200,000 | 7ថ្ងៃ | 1ឆ្នាំ |
| 21 | សារបង្ហាន់ដៃ | 40,000 | 5ថ្ងៃ | 3-6ខែ |
| 22 | ប័ណ្ណព័ត៌មានសម្រាប់អ្នកកាសែត | | | |
| | - ជនជាតិខ្មែរ | 5,000 | 2ថ្ងៃ | 3ខែ |
| | - ជនជាតិបរទេស | 20,000 | 2ថ្ងៃ | 3ខែ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 23 | សេវាសោតទស្សន៍ស្ថានីយវិទ្យុ មានកម្លាំងផ្សាយ | | | |
| | - ចាប់ពី 100w ដល់ 2000w | 1,000,000 | | 1ឆ្នាំ |
| | - លើសពី 2000w ដល់ 5000w | 1,500,000 | | 1ឆ្នាំ |
| | - លើសពី 5000w ដល់ 10000w | 3,000,000 | | 1ឆ្នាំ |
| | - លើសពី 10000w | 4,000,000 | | 1ឆ្នាំ |
| 24 | សេវាសោតទស្សន៍ស្ថានីយវិទ្យុផ្សាយបន្ត | 500,000 | | 1ឆ្នាំ |
| 25 | សេវាសោតទស្សន៍ស្ថានីយទូរទស្សន៍ មានកម្លាំងផ្សាយ | | | |
| | - ចាប់ពី 100w ដល់ 2000w | 3,000,000 | | 1ឆ្នាំ |
| | - លើសពី 2000w ដល់ 5000w | 4,000,000 | | 1ឆ្នាំ |
| | - លើសពី 5000w ដល់ 10000w | 5,000,000 | | 1ឆ្នាំ |
| | - លើសពី 10000w | 10,500,000 | | 1ឆ្នាំ |
| 26 | សេវាសោតទស្សន៍ស្ថានីយទូរទស្សន៍ផ្សាយបន្ត | 1,000,000 | | 1ឆ្នាំ |
| 27 | សេវាសោតទស្សន៍ស្ថានីយទូរទស្សន៍ផ្សាយតាមប្រព័ន្ធផ្សេងៗ (ខ្សែកាប, MMDS, MUDS...) | | | |
| | - នៅរាជធានីភ្នំពេញ | 7,000,000 | | 1ឆ្នាំ |
| | - ដែលប្រកបអាជីវកម្មក្នុងកំរិតស្រុក ឬឃុំសង្កាត់ | 1,000,000 | | 1ឆ្នាំ |
| 28 | ផ្សាយ Spot ពាណិជ្ជកម្មតាមវិទ្យុជាតិកម្ពុជា | | | |
| | - តម្លៃទាបបំផុត (ក្នុង 1នាទី) | 4,000 | | |
| | - តម្លៃខ្ពស់បំផុត (ក្នុង 1នាទី) | 6,000 | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 29 | ផ្សាយ ដំណឹងផ្សេងៗតាមវិទ្យុជាតិកម្ពុជា | | | |
| | - តម្លៃទាបបំផុត (1ទំព័រA4) | 3,000 | | |
| | - តម្លៃខ្ពស់បំផុត (1ទំព័រA4) | 5,000 | | |
| 30 | ផ្សាយ Spot ពាណិជ្ជកម្មតាមទូរទស្សន៍ជាតិកម្ពុជា | | | |
| | - តម្លៃទាបបំផុត (30វិនាទី) | 32,000 | | |
| | - តម្លៃខ្ពស់បំផុត (30វិនាទី) | 60,000 | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០០៤ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១២

# ប្រកាសរួម
## ស្តីពី
## ការផ្តល់ទឹកប្រាក់លើកទឹកចិត្តជូន
## ក្រសួងព័ត៌មាន និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងព័ត៌មាន



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងប្រកាសរួមលេខ ១០០៣ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងព័ត៌មាន

## សម្រេច

**ប្រការ ១** :

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនក្រសួងព័ត៌មាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ ២** :

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា រវាងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងព័ត៌មាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននៃការបែងចែកភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងការផ្តល់សេវាសាធារណៈដែលអនុវត្តដោយមន្ទីរជំនាញរាជធានី ខេត្ត។

**ប្រការ ៣** :

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលនៃក្រសួងព័ត៌មាន និងមន្ទីរព័ត៌មានរាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួនពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ១០០៣ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងព័ត៌មាន។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនរដ្ឋបាលកណ្តាលនៃក្រសួងព័ត៌មាន និងមន្ទីរព័ត៌មានរាជធានី ខេត្ត សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងព័ត៌មាន និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៤** :

ការផ្តល់ប្រាក់រង្វាន់ជូនក្រសួងព័ត៌មាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ៖

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងព័ត៌មាន តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនមន្ទីរព័ត៌មានរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ

**ប្រការ ៥** :

រដ្ឋបាលកណ្តាលនៃក្រសួងព័ត៌មាន និងមន្ទីរព័ត៌មានរាជធានី ខេត្ត ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលនៃក្រសួងព័ត៌មាន ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីរព័ត៌មានរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងព័ត៌មានដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ(ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. ផ្នែកចំណូលៈត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន ៖

- ចំពោះរដ្ឋបាលកណ្តាលនៃក្រសួងព័ត៌មានត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។
- ចំពោះមន្ទីរព័ត៌មានរាជធានី ខេត្តត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

ខ. ផ្នែកចំណាយៈ ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ ៦** :

ក្រោយពីបានបំពេញនីតិវិធី ដែលមានចែងក្នុងប្រការ ៥ ខាងលើ ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តត្រូវអនុវត្ត ដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងព័ត៌មាន ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ ៧** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងព័ត៌មាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

**ខៀវ កាញារីទ្ធ**

ចម្លងជូន:

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត

«ដើម្បីជូនជ្រាប»

- ដូចប្រការ ៨ «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ

## ភ្ជាប់នឹងប្រកាសរួមលេខ ១០០៤ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

## ស្តីពីការផ្តល់ទ្វាន់លើកទឹកចិត្ត ជូនក្រសួងព័ត៌មាន(ក. ពម) និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ក. សហវ)

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. ពម | ក. សហវ |
| 1 | ផ្សព្វផ្សាយពាណិជ្ជកម្មតាមប៉ាណូ | | | |
| | - រយៈពេល 1ឆ្នាំ | 50% | 49% | 1% |
| | - រយៈពេល 6ខែ | 50% | 49% | 1% |
| | - រយៈពេល 3ខែ | 50% | 49% | 1% |
| 2 | ផ្សព្វផ្សាយពាណិជ្ជកម្មតាមមធ្យោបាយដឹកជញ្ជូនផ្សេងៗ | | | |
| | - រយៈពេល 1ឆ្នាំ | 50% | 49% | 1% |
| | - រយៈពេល 6ខែ | 50% | 49% | 1% |
| | - រយៈពេល 3ខែ | 50% | 49% | 1% |
| 3 | ផ្សព្វផ្សាយពាណិជ្ជកម្មតាមអាហ្វីស | 50% | 49% | 1% |
| 4 | ផ្សព្វផ្សាយពាណិជ្ជកម្មតាមប័ណ្ណប្រកាស (គ្រាន់តែផ្តល់គំរូប័ណ្ណប្រកាសមកក្រសួង/មន្ទីរព័ត៌មាន) | 0% | 0% | 0% |
| 5 | ភ្នាក់ងារផ្សព្វផ្សាយពាណិជ្ជកម្ម | | | |
| | - បើក | 50% | 49% | 1% |
| | - បន្តសុពលភាព | 50% | 49% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. ពម | ក. សហវ |
| 6 | វាល់លិខិតអនុញ្ញាតសម្រាប់ឃោសនាមហាជន | 0% | 0% | 0% |
| 7 | អាជីវកម្មគ្រឹះស្ថានបោះពុម្ពផ្សាយ | | | |
| | - បើក | 50% | 49% | 1% |
| | - បន្តសុពលភាព | 50% | 49% | 1% |
| 8 | អាជីវកម្មរោងពុម្ព | | | |
| | - បើក | 50% | 49% | 1% |
| | - បន្តសុពលភាព | 50% | 49% | 1% |
| 9 | សមាគមវិទ្យុ និងទូរទស្សន៍ | | | |
| | - បើក | 50% | 49% | 1% |
| | - បន្តសុពលភាព | 50% | 49% | 1% |
| 10 | - បើកអាជីវកម្មស្ថានីយវិទ្យុផ្សាយផ្ទាល់, វិទ្យុផ្សាយបន្ត, ទូរទស្សន៍ផ្សាយផ្ទាល់-បន្ត, ទូរទស្សន៍ខ្សែកាប និងទូរទស្សន៍ផ្សាយតាមប្រព័ន្ធផ្សេងៗ (MMDS, MUDS...) | 0% | 0% | 0% |
| | - បន្តសុពលភាពអាជីវកម្មស្ថានីយវិទ្យុផ្សាយផ្ទាល់ | 50% | 49% | 1% |
| | - បន្តសុពលភាពអាជីវកម្មស្ថានីយវិទ្យុផ្សាយបន្ត | 50% | 49% | 1% |
| | - បន្តសុពលភាពអាជីវកម្មស្ថានីយទូរទស្សន៍ផ្សាយផ្ទាល់ | 50% | 49% | 1% |
| | - បន្តសុពលភាពអាជីវកម្មស្ថានីយទូរទស្សន៍ផ្សាយបន្ត | 50% | 49% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. ពម | ក. សហវ |
| | - បន្តសុពលភាពអាជីវកម្មស្ថានីយទូរទស្សន៍ផ្សាយតាមប្រព័ន្ធផ្សេងៗ (ខ្សែកាប, MMDS, MUDS...) នៅរាជធានីភ្នំពេញ | 50% | 49% | 1% |
| | - បន្តសុពលភាពអាជីវកម្មស្ថានីយទូរទស្សន៍ផ្សាយតាមប្រព័ន្ធផ្សេងៗ(ខ្សែកាប, MMDS, MUDS...) កំរិតស្រុក ឬឃុំសង្កាត់ | 50% | 49% | 1% |
| 11 | អាជីវកម្មផ្សាយតាមប្រព័ន្ធអេឡិចត្រូនិច | | | |
| | - បើក | 50% | 49% | 1% |
| | - បន្តសុពលភាព | 50% | 49% | 1% |
| 12 | សេវាត្រួតពិនិត្យ | | | |
| | - ស្ថានីយវិទ្យុប្រចាំឆ្នាំ | 50% | 49% | 1% |
| | - ស្ថានីយទូរទស្សន៍ប្រចាំឆ្នាំ | 50% | 49% | 1% |
| | - ពិសេសបន្ទាន់តាមស្ថានីយវិទ្យុ ទូរទស្សន៍ | 50% | 49% | 1% |
| 13 | អាជីវកម្មកាសែតផ្សាយភាសាជាតិ ឬភាសាបរទេស | | | |
| | - បើក | 50% | 49% | 1% |
| | - បន្តសុពលភាព | 50% | 49% | 1% |
| 14 | អាជីវកម្មកាសែតផ្សាយជាភាសាបរទេស និងភាសាជាតិ | | | |
| | - បើក | 50% | 49% | 1% |
| | - បន្តសុពលភាព | 50% | 49% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. ពម | ក. សហវ |
| 15 | អាជីវកម្មទស្សនាវដ្តី | | | |
| | - បើក(ភាសាជាតិ) | 50% | 49% | 1% |
| | - បើក (ភាសាបរទេស ឬភាសាជាតិ និងបរទេស) | 50% | 49% | 1% |
| | - បន្តសុពលភាព | 50% | 49% | 1% |
| 16 | អាជីវកម្មព្រឹត្តបត្រភាសាជាតិ | | | |
| | - បើក(ភាសាជាតិ) | 50% | 49% | 1% |
| | - បើក (ភាសាបរទេស ឬភាសាជាតិ និងបរទេស) | 50% | 49% | 1% |
| | - បន្តសុពលភាព | 50% | 49% | 1% |
| 17 | ប្តូរឈ្មោះកាសែតភាសាជាតិ កាសែតភាសាបរទេស, ទស្សនាវដ្តីភាសាជាតិ | 50% | 49% | 1% |
| 18 | ផ្ទេរសិទ្ធិកាសែត, ទស្សនាវដ្តីព្រឹត្តបត្រភាសាជាតិ និងភាសាបរទេស | 50% | 49% | 1% |
| 19 | អាជីវកម្មនាំចូលកាសែត និងទស្សនាវដ្តី | | | |
| | - បើក | 50% | 49% | 1% |
| | - បន្តសុពលភាព | 50% | 49% | 1% |
| 20 | បង្កើតសមាគមសារព័ត៌មាន | 50% | 49% | 1% |
| 21 | សារបង្ហាន់ដៃ | 50% | 49% | 1% |
| 22 | ប័ណ្ណព័ត៌មានសម្រាប់អ្នកកាសែត | | | |
| | - ជនជាតិខ្មែរ | 10% | 89% | 1% |
| | - ជនជាតិបរទេស | 10% | 89% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. ពម | ក. សហវ |
| 23 | សេវាសោតទស្សន៍ស្ថានីយវិទ្យុ មានកម្លាំងផ្សាយ | | | |
| | - ចាប់ពី 100w ដល់ 2000w | 50% | 49% | 1% |
| | - លើសពី 2000w ដល់ 5000w | 50% | 49% | 1% |
| | - លើសពី 5000w ដល់ 10000w | 50% | 49% | 1% |
| | - លើសពី 10000w | 50% | 49% | 1% |
| 24 | សេវាសោតទស្សន៍ស្ថានីយវិទ្យុផ្សាយបន្ត | 50% | 49% | 1% |
| 25 | សេវាសោតទស្សន៍ស្ថានីយទូរទស្សន៍ មានកម្លាំងផ្សាយ | | | |
| | - ចាប់ពី 100w ដល់ 2000w | 50% | 49% | 1% |
| | - លើសពី 2000w ដល់ 5000w | 50% | 49% | 1% |
| | - លើសពី 5000w ដល់ 10000w | 50% | 49% | 1% |
| | - លើសពី 10000w | 50% | 49% | 1% |
| 26 | សេវាសោតទស្សន៍ស្ថានីយទូរទស្សន៍ផ្សាយបន្ត | 50% | 49% | 1% |
| 27 | សេវាសោតទស្សន៍ស្ថានីយទូរទស្សន៍ផ្សាយតាមប្រព័ន្ធផ្សេងៗ (ខ្សែកាប, MMDS, MUDS...) | | | |
| | - នៅរាជធានីភ្នំពេញ | 50% | 49% | 1% |
| | - ដែលប្រកបអាជីវកម្មក្នុងកំរិតស្រុក ឬឃុំសង្កាត់ | 50% | 49% | 1% |
| 28 | ផ្សាយ Spot ពាណិជ្ជកម្មតាមវិទ្យុជាតិកម្ពុជា | | | |
| | - តម្លៃទាបបំផុត (ក្នុង 1នាទី) | 10% | 89% | 1% |
| | - តម្លៃខ្ពស់បំផុត (ក្នុង 1នាទី) | 10% | 89% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. ពម | ក. សហវ |
| 29 | ផ្សាយ ដំណឹងផ្សេងៗតាមវិទ្យុជាតិកម្ពុជា | | | |
| | - តម្លៃទាបបំផុត (1ទំព័រA4) | 10% | 89% | 1% |
| | - តម្លៃខ្ពស់បំផុត (1ទំព័រA4) | 10% | 89% | 1% |
| 30 | ផ្សាយ Spot ពាណិជ្ជកម្មតាមទូរទស្សន៍ជាតិកម្ពុជា | | | |
| | - តម្លៃទាបបំផុត (30វិនាទី) | 10% | 89% | 1% |
| | - តម្លៃខ្ពស់បំផុត (30វិនាទី) | 10% | 89% | 1% |

**បញ្ជាក់:** ចំពោះចំណូលដែលប្រមូលបានពីការផ្តល់សេវាសាធារណៈដោយមន្ទីរព័ត៌មានរាជធានី ខេត្ត ការផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ទីរព័ត៌មានរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវអនុវត្តដូចអត្រាដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនេះ។